ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...១៧០៨៦.....អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបំពេញបែបបទចូលបម្រើការងាររបស់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ “ក” និង “ខ” ចំនួន ២៨០នាក់ ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ “ក” និង “ខ” ចំនួន២៨០នាក់ ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នាសម័យប្រឡងថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០១៤ មណ្ឌលប្រឡងវិទ្យាល័យព្រះស៊ីសុវត្ថិជ្រាបថា៖ បេក្ខជនត្រូវមកបំពេញបែបបទចូលបម្រើការងារនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤ វេលាម៉ោង ០៨.០០ (ព្រឹក) នៅអគារសាលាជាតិពន្ធដារ ជាន់ទី១០។ ទន្ទឹមនោះ បេក្ខជនទាំងពីរភេទនឹងត្រូវចាប់ផ្តើមចូលរៀនវគ្គបណ្តុះបណ្តាលជំនាញពន្ធដារចាប់ពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤តទៅ។

អាស្រ័យហេតុនេះ សូមបេក្ខជនដែលប្រឡងជាប់ជាស្ថាពរ ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារទាំងអស់ អញ្ជើញមកបំពេញបែបបទចូលបម្រើការងារតាមពេលវេលា និងទីកន្លែងដែលបានកំណត់កុំបីខាន ។

អាសយដ្ឋានសាលាជាតិពន្ធដារ៖ អគារលេខ៤៧-៤៣ ផ្លូវលេខ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយករង

ឃុន ស៊ីម៉ារ៉េត


**ទំនាក់ទំនង** ៖
ទូរស័ព្ទលេខ: ០២៣ ៨៨១ ៩១០
Email: nts@tax.gov.kh